ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ
# ស្តីពី
# ការកសាងផែនការសកម្មភាព ថ្នាក់ក្រោមជាតិ សម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច

អគ្គលេខាធិការដ្ឋាន
នៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
២០២៥

unicef
ដើម្បីកុមារគ្រប់រូប

# មាតិកា

**បុព្វកថា** ........ iii
**សេចក្តីផ្តើម** ........ v

**ជំពូកទី១ ៖ ការបង្កើតក្រុមការងាររកសាងផែនការសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច** ........ ១
១. ដំណើរការបង្កើតក្រុមការងាររកសាងផែនការសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច ........ ១

**ជំពូកទី២ ៖ ការវិភាគស្ថានភាពកុមារពី 0 ដល់ក្រោម ៦ឆ្នាំ** ........ ៣
១. ការផ្តួចផ្តើមគំនិត ........ ៣
២. វិភាគទិន្នន័យដែលមានស្រាប់ ........ ៣
៣. វិភាគឯកសារក្របខ័ណ្ឌគតិយុត្ត ........ ៤
៤. ប្រមូលទិន្នន័យភស្តុតាងពីសហគមន៍ ........ ៥

**ជំពូកទី៣ ៖ ការរៀបចំ អនុម័ត និងផ្សព្វផ្សាយផែនការសកម្មភាព** ........ ៩
១. ការរៀបចំសេចក្តីព្រាងផែនការសកម្មភាព ........ ៩
២. ការផ្ទៀតផ្ទាត់ និងបញ្ចប់ផែនការសកម្មភាព ........ ១០
៣. ការអនុម័ត និងផ្សព្វផ្សាយ ........ ១១

**ឧបសម្ព័ន្ធ ក ៖ តារាងផែនការសកម្មភាព និងគម្រោងចំណាយ** ........ ១៣
**ឧបសម្ព័ន្ធ ខ ៖ តារាងក្របខណ្ឌតាមដាន និងវាយតម្លៃ និងតារាងតក្កវិជ្ជា** ........ ១៤
**ឧបសម្ព័ន្ធ គ ៖ ឯកសារក្របខ័ណ្ឌគតិយុត្ត** ........ ១៥
**ឧបសម្ព័ន្ធ ឃ ៖ គម្រូងសំណួរប្រមូលទិន្នន័យភស្តុតាងពីសហគមន៍** ........ ១៦
**ឧបសម្ព័ន្ធ ង ៖ ទម្រង់គំរូសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងាររកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូច** ........ ១៩

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យផ្តល់សេវាគាំពារ និងអភិវឌ្ឍន៍ប្រកបដោយគុណភាព និងបរិយាបន្ន ដល់កុមារទាំងអស់ចាប់ពីកកំណើតរហូតដល់អាយុក្រោម៦ឆ្នាំ ជាពិសេសកុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ និងក្រខ្សត់ ស្របតាមគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច បានអនុម័តជាផ្លូវការនូវផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលជាផែនទីបង្ហាញផ្លូវដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា សម្រាប់អនុវត្តស្របតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវរៀងៗខ្លួន។ ដោយឡែករដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលរាជធានី ខេត្ត តម្រូវឱ្យរៀបចំផែនការសកម្មភាពសម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដើម្បីធានាគណនេយ្យភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅតាមមូលដ្ឋានរបស់រាជធានី ខេត្តសាមី ឱ្យកាន់តែប្រសើរឡើង និងគ្រប់ជ្រុងជ្រោយ ។

ផ្អែកលើមូលដ្ឋាននេះ គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច បានសហការជាមួយអង្គការយូនីសេហ្វ រៀបចំសៀវភៅណែនាំស្តីពី ការកសាងផែនការសកម្មភាពថ្នាក់ក្រោមជាតិសម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ក្នុងគោលបំណងលើកកម្ពស់ និងផ្តល់ជាមគ្គុទ្ទេសក៍សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំបង្កើតក្រុមការងារកសាងផែនការសកម្មភាព ការវិភាគស្ថានភាពកុមារអាយុពី ០ ដល់អាយុក្រោម ៦ឆ្នាំ និងការរៀបចំ អនុម័ត និងផ្សព្វផ្សាយផែនការសកម្មភាពដែលធានាបាននូវសង្គតិភាព និងមានលក្ខណៈជាប្រព័ន្ធ ព្រមទាំងយន្តការច្បាស់លាស់នៅក្នុងក្របខ័ណ្ឌគតិយុត្តប្រកបដោយនីត្យានុកូលភាព។

ក្នុងនាមគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច គណៈកម្មការសម្របសម្រួលបច្ចេកទេសអន្តរក្រសួង និងអង្គការយូនីសេហ្វ ដែលបានគាំទ្រទាំងបច្ចេកទេសនិងធនធាន រហូតសម្រេចបាននូវសៀវភៅណែនាំនេះឡើង។ ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នៃគណៈកម្មការសម្របសម្រួលបច្ចេកទេសអន្តរក្រសួង អង្គការជាតិ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេស ដែលបានចូលរួមយ៉ាងសកម្មនិងផ្តល់ធាតុចូលដ៏មានតម្លៃ ប្រកបដោយការទទួលខុសត្រូវខ្ពស់។ ខ្ញុំសូមលើកទឹកចិត្តឱ្យបន្តកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួលនិងជំរុញការអនុវត្តផែនការសកម្មភាពឱ្យសម្រេចបានតាមលទ្ធផលគ្រោងទុក។

ថ្ងៃ សុក្រ ៧រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**និងជាប្រធានគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច**

បណ្ឌិតសត្ថាចារ្យ **ហង់ជួន ណារ៉ុន**

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ និងបន្តផ្តល់អាទិភាពលើការអភិវឌ្ឍធនធានមនុស្សដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១-ទី៤ និងយុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១ ក៏ដូចជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ ស្របតាមគោលនយោបាយអភិវឌ្ឍន៍ធនធាន មនុស្ស និងដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍មូលធនមនុស្សរយៈពេលវែង ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យប្រែក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ឆ្នាំ២០៥០ រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅឆ្នាំ២០១០។ ដើម្បីអនុវត្តគោល-នយោបាយជាតិនេះអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច(គ.ជ.គ.ក) បានរៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ២០១៤-២០១៨ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ២០២២-២០២៦។ ក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកគណៈកម្មាធិការជាតិ ចូលរួមអនុវត្តផែនការសកម្មភាពជាតិនេះ តាមរយៈការបញ្ជ្រាបសកម្មភាពអាទិភាពឆ្លើយតបនឹងការគាំពារនិងអភិវឌ្ឍកុមារតូច ទៅក្នុងគោលនយោបាយ និងផែនការយុទ្ធសាស្រ្តតាមវិស័យ និងអន្តរវិស័យពាក់ព័ន្ធ។

ស្របតាមគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងផែនការសកម្មភាពស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាពសម្រាប់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច តាមរាជធានី ខេត្ត។ ផែនការ សកម្មភាពនេះត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធរួមមានមន្ទីរជំនាញនៃក្រសួងស្ថាប័នដែលជាសមាជិកគ.ជ.គ.ករដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ប្រជាពលរដ្ឋ ជាពិសេសមាតាបិតា ឬអាណាព្យាបាល ព្រមទាំងកុមារផងដែរ។ ផែនការសកម្មភាពថ្នាក់ក្រោមជាតិនីមួយៗ មានតួនាទីជួយសម្រួល និងជម្រុញដល់ការប្រែក្លាយគោលនយោបាយ និងយុទ្ធសាស្រ្តជាតិ ទៅជាសកម្មភាពជាក់ស្តែងឆ្លើយតបនឹងបញ្ហាអាទិភាពនៅតាមភូមិសាស្រ្ត និងមូលដ្ឋាននីមួយៗ និងជាផែនទីបង្ហាញផ្លូវសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាប្រឈម និងផ្តល់សេវាចំគោលដៅដែលជាតម្រូវការរបស់កុមារតូច និងមាតាបិតាឬអាណាព្យាបាល។ ការប្រែក្លាយគោល-នយោបាយជាតិ ឱ្យទៅជាផែនការសកម្មភាពថ្នាក់ក្រោមជាតិនៅមូលដ្ឋាននឹងធានាថា កម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូចនានាមិនត្រឹមតែមានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ពលរដ្ឋ ជាពិសេស ស្ត្រី និងកុមារ នៅតាមសហគមន៍មូលដ្ឋាន។

ដើម្បីផ្តល់នូវការតម្រង់ទិស និងការណែនាំបច្ចេកទេស ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច អគ្គលេខាធិការដ្ឋាននៃ គ.ជ.គ.ក បានរៀបចំជាសៀវភៅណែនាំស្តីពី ការកសាងផែនការសកម្មភាពថ្នាក់ក្រោមជាតិ សម្រាប់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច។ សៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងស្របតាមគោលនយោបាយជាតិរបស់ កម្ពុជាស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូច ក្របខ័ណ្ឌចិញ្ចឹមបីបាច់កុមារតូចសកល និងដោយផ្អែកលើបទពិសោធ និងការអនុវត្តសាកល្បងរបស់រដ្ឋបាលខេត្តក្រចេះ កំពង់ចាម និងខេត្តរតនគិរី ក្នុងការកសាងផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។

រដ្ឋបាលរាជធានី ខេត្ត ត្រូវធានានូវសង្គតិភាព និងសុខដុមនីយកម្មនៃផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ទៅនឹងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ និងផែនការសកម្មភាព និងយុទ្ធសាស្ត្ររបស់មន្ទីរជំនាញពាក់ព័ន្ធ ដើម្បីឱ្យមានភាពជាម្ចាស់លើសកម្មភាពដែលមានលើកឡើងនៅក្នុងផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។ ក្របខ័ណ្ឌពេលវេលានៃផែនការសកម្មភាពនេះត្រូវមានរយៈពេលបីឆ្នាំដែលស្របនឹងក្របខ័ណ្ឌពេលវេលានៃកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផែនការសកម្មភាពនេះត្រូវរៀបចំឱ្យបានមុនកម្មវិធីវិនិយោគបីឆ្នាំរំកិល ដើម្បីផ្តល់ឱកាសឱ្យភាគីពាក់ព័ន្ធអាចបញ្ចូលសកម្មភាពពាក់ព័ន្ធការគាំពារ និងអភិវឌ្ឍន៍កុមារតូច ទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

រដ្ឋបាលរាជធានី ខេត្ត ដោយមានការចូលរួមពីមន្ទីរពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវខិតខំយកចិត្តទុកដាក់ និងប្រឹងប្រែងឱ្យអស់ពីសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ព្រមទាំងការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្សកម្ពុជា ឱ្យក្លាយជាកម្លាំងពលកម្មដែលមានសមត្ថភាពប្រកួតប្រជែងក្នុងតំបន់ ពិភពលោក និងស្របតាមចក្ខុវិស័យដ៏ភ្លឺថ្លារបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលផ្តល់អាទិភាពចម្បងលើមនុស្ស។

## សៀវភៅណែនាំនេះបែងចែកជា បីជំហានធំៗ គឺ៖

១ ការបង្កើតក្រុមការងារកសាងផែនការសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច

២ ការវិភាគស្ថានភាពកុមារពី 0 ដល់ក្រោម ៦ឆ្នាំ

៣ ការរៀបចំ អនុម័ត និងផ្សព្វផ្សាយផែនការសកម្មភាព

## ជំហានទី១

# ការបង្កើតក្រុមការងារកសាងផែនការសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច

## ១. ដំណើរការបង្កើតក្រុមការងារកសាងផែនការសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច

គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច បានចែងយ៉ាងច្បាស់ថា កិច្ចគាំពារ និងអភិវឌ្ឍកុមារតូចនឹងត្រូវអនុវត្តដោយគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅថ្នាក់ជាតិ និងដោយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ រាជធានី ខេត្តនៅថ្នាក់ក្រោមជាតិ។

**នៅថ្នាក់ជាតិតំណាងមកពីក្រសួងចំនួន១២** ជាសមាជិកនៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូចរួមមាន៖

១. ក្រសួងអប់រំ យុវជន និងកីឡា

២. ក្រសួងសុខាភិបាល

៣. ក្រសួងមហាផ្ទៃ

៤. ក្រសួងកិច្ចការនារី

៥. ក្រសួងព័ត៌មាន

៦. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៧. ក្រសួងអភិវឌ្ឍន៍ជនបទ

៨. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៩. ក្រសួងផែនការ

១០. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១១. ក្រសួងបរិស្ថាន

១២. ទីស្តីការគណៈរដ្ឋមន្ត្រី

គោលនយោបាយជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូច ក៏រួមបញ្ចូលភាគីពាក់ព័ន្ធផ្សេងទៀត រួមមាន មាតាបិតា ឬអាណាព្យាបាល អង្គការដៃគូ និងសង្គមស៊ីវិលផងដែរ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារកសាងផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច (ហៅកាត់ថាក្រុមការងារ) ដែលមានសមាសភាពរួមមាន៖

| ប្រធាន<br>ឬអនុប្រធានមន្ទីរទាំង១០ | នាយក ឬនាយករងរដ្ឋបាល ទីចាត់ការផែនការនិងវិនិយោគ<br>ទីចាត់ការហិរញ្ញវត្ថុ និងទីចាត់ការអន្តរវិស័យ។ |
|---|---|

ក្រុមការងារនេះត្រូវដឹកនាំដោយប្រធាន គ.ក.ស.ក. រាជធានី ខេត្ត និងមានអភិបាលរងនៃរដ្ឋបាលរាជធានី ខេត្ត ជាស្ត្រីជាអនុប្រធានប្រចាំការ ដែលអាចអញ្ជើញភាគីពាក់ព័ន្ធថ្នាក់ ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមផ្តល់ធាតុចូលក្នុងដំណើរការកសាងផែនការសកម្មភាពតាមស្ថានភាពជាក់ស្តែង និងសមស្រប។

ក្រុមការងារនេះត្រូវមានទីចាត់ការផែនការនិងវិនិយោគ ជាលេខាធិការដ្ឋានដើម្បីសម្របសម្រួល និងដឹកនាំក្រុមការងារបច្ចេកទេសដែលមានសមាសភាពមកពីមន្ទីរ និងទីចាត់ការពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាព។ ក្រុមការងារបច្ចេកទេសត្រូវមានមន្ត្រីបច្ចេកទេស ឬមន្ត្រីបង្គោលដែលជាតំណាងមកពីមន្ទីរទាំង១០ និងទីចាត់ការពាក់ព័ន្ធរបស់រដ្ឋបាលរាជធានី ខេត្ត។

ទម្រង់គំរូសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារកសាងផែនការសកម្មភាពមាននៅក្នុង

**ឧបសម្ព័ន្ធ ង ។**

## ជំហានទី២
## ការវិភាគស្ថានភាពកុមារពី ០ ដល់ក្រោម ៦ឆ្នាំ

### ១. ការផ្តួចផ្តើមគំនិត

ក្រុមការងារកសាងផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដូចមានចែងក្នុងជំហានទី១ ត្រូវបានចាត់តាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សារាជធានី ខេត្ត។ ក្រុមការងារចាប់ផ្តើមកសាងផែនការសកម្មភាពដោយផ្អែកលើជំហានសំខាន់ៗដូចខាងក្រោម៖




### ២. វិភាគទិន្នន័យដែលមានស្រាប់

ក្រុមការងារបច្ចេកទេសដែលមានមន្ទីរផែនការជាសេនាធិការ ដឹកនាំការងារវិភាគស្ថានភាពស្ត្រីនិងកុមារអាយុ០ ដល់ក្រោម៦ឆ្នាំដោយប្រើប្រាស់ទិន្នន័យរដ្ឋបាលដូចជា សៀវភៅទិន្នន័យឃុំ/សង្កាត់ (CDB) ប្រព័ន្ធគ្រប់គ្រងព័ត៌មានព្រីម៉េរ៉ូ (PRIMERO) ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (EMIS) ប្រព័ន្ធព័ត៌មានគ្រប់គ្រងសុខាភិបាល (HMIS), ប្រព័ន្ធគ្រប់គ្រងព័ត៌មានអត្តសញ្ញាណកម្មពិការភាព (DMIS), អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS), ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា (GPCC) និងទិន្នន័យរដ្ឋបាល ឬអង្កេតរបស់ក្រសួង ស្ថាប័ន និងមន្ទីរពាក់ព័ន្ធដែលមានស្រាប់។

នៅក្នុងដំណើរការវិភាគ ប្រធានក្រុមការងារបច្ចេកទេសត្រូវរៀបចំកិច្ចប្រជុំ ដោយមានការចូលរួមពីមន្ទីរផែនការ មន្ទីរជំនាញនិងទីចាត់ការពាក់ព័ន្ធ និងភាគីពាក់ព័ន្ធផ្សេងទៀត។ នៅក្នុងកិច្ចប្រជុំក្រុមការងារត្រូវពិភាក្សាលើរបៀបវារៈសំខាន់ៗដូចខាងក្រោម៖

- ការជ្រើសរើសសូចនាករពាក់ព័ន្ធនឹងស្ត្រីនិងកុមារដែលមាននៅក្នុងផែនការសកម្មភាពជាតិ
- ពិនិត្យប្រភពទិន្នន័យដែលមានស្រាប់សម្រាប់ប្រើប្រាស់ក្នុងការវិភាគ
- សម្រង់លើឯកសារស្រាវជ្រាវ និងរបាយការណ៍ពាក់ព័ន្ធ
- កំណត់ឱសានវាទនៃការវិភាគ និងការធ្វើបទបង្ហាញលទ្ធផល។

នៅក្នុងអំឡុងពេលវិភាគ មន្ទីរផែនការត្រូវផ្ដោតលើចំនុចសំខាន់ៗដូចខាងក្រោម៖

- វឌ្ឍនភាពដោយប្រើទិន្នន័យប្រាំឆ្នាំចុងក្រោយ និងបញ្ហាតាមវិស័យ
- បញ្ហាដែលមិនទាន់មានភស្តុតាងច្បាស់លាស់និងដែលត្រូវប្រើវិធីសាស្ត្រផ្សេងទៀតរួមទាំងការវិភាគដើមឈើនៃបញ្ហា ( Problem Tree Analysis/Causality Analysis )
- រៀបចំផែនការប្រមូលទិន្នន័យបន្ថែមដោយប្រើប្រាស់កម្រងសំណួរប្រមូលទិន្នន័យភស្តុតាងពីសហគមន៍ដែលមានក្នុងឧបសម្ព័ន្ធ «គ»
- ដឹកនាំក្រុមការងារប្រមូលទិន្នន័យ។

## ៣. វិភាគឯកសារក្របខ័ណ្ឌគតិយុត្ត

**ឯកសារក្របខ័ណ្ឌគតិយុត្ត** គឺជាឯកសារទាំងឡាយណា ដែលមានទម្រង់ជាគោលនយោបាយ ក្របខ័ណ្ឌ យុទ្ធសាស្ត្រ សៀវភៅណែនាំ មេរៀន និងផែនការសកម្មភាពពាក់ព័ន្ធទៅនឹងកិច្ចការគាំពារ និងអភិវឌ្ឍន៍កុមារតូច។ ក្រៅពីឯកសារក្របខ័ណ្ឌគតិយុត្តជាតិ ក្រុមការងារក៏ត្រូវប្រមូល និងវិភាគឯកសារស្រាវជ្រាវ និងរបាយការណ៍នានាស្ដីពីឧត្តមានុវត្តន៍នៃសេវាគាំពារនិងអភិវឌ្ឍន៍កុមារតូច ពីបណ្ដារាជធានីខេត្ត ផ្សេងៗទៀត នៅក្នុងប្រទេស ដើម្បីជាធាតុចូលផងដែរ។ សូមមើលបញ្ជីឯកសារដែលត្រូវអាន និងវិភាគក្នុងឧបសម្ព័ន្ធ «គ»។

### ក. គោលការណ៍នៃការវិភាគ និងយោងឯកសារក្របខ័ណ្ឌគតិយុត្ត

ការវិភាគឯកសារក្របខ័ណ្ឌគតិយុត្ត និងឯកសារស្រាវជ្រាវនានានឹងផ្ដល់អត្ថប្រយោជន៍ច្រើនសម្រាប់ជាធាតុចូលក្នុងការកសាងផែនការសកម្មភាពថ្នាក់ក្រោមជាតិស្ដីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដោយផ្អែកលើគោលការណ៍៖

- **សម្រេចចិត្តដោយមានភស្តុតាងច្បាស់លាស់៖** ការវិភាគឯកសារក្របខ័ណ្ឌគតិយុត្ត ឯកសារស្រាវជ្រាវនានា របាយការណ៍វិភាគស្ថានភាពរួមទាំងការប្រមូលភស្តុតាងបន្ថែមពីក្រុមគោលដៅដែលជាអ្នកផ្ដល់សេវា និងទទួលសេវាគាំពារ និងអភិវឌ្ឍកុមារតូចនឹងផ្ដល់ចំណេះដឹងមូលដ្ឋានរឹងមាំដល់សមាជិកក្រុមការងារកសាងផែនការអំពីគោលការណ៍ គោលនយោបាយ ក្របខ័ណ្ឌ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងឧត្តមានុវត្តន៍អំពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចទាំងថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។
- **បន្សុីគ្នាជាមួយនឹងគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ៖** ការវិភាគឯកសារទាំងនេះនឹងធ្វើឱ្យសមាជិកក្រុមការងារអាចធានាបានថាផែនការសកម្មភាពថ្នាក់ក្រោមជាតិនឹងមានសង្គតិភាពជាមួយនឹងគោលនយោបាយ និងផែនការសកម្មភាពជាតិ។
- **រៀនសូត្រពីឧត្តមានុវត្តន៍៖** ការវិភាគឯកសារទាំងនេះនឹងធ្វើឱ្យក្រុមការងារអាចកត់សម្គាល់បានអំពីយុទ្ធសាស្ត្រ អន្តរាគមន៍ និងបទពិសោធល្អដែលគេបានអនុវត្តយ៉ាងជោគជ័យកន្លងមកទាំងអំពីការកសាងផែនការ និងការផ្ដល់សេវាគាំពារនិងអភិវឌ្ឍន៍កុមារតូច។

### ខ. ជំហានសម្រាប់ការវិភាគឯកសារក្របខ័ណ្ឌគតិយុត្ត

ដើម្បីធ្វើឱ្យការវិភាគឯកសារទទួលបានជោគជ័យ សមាជិកនៃក្រុមការងារកសាងផែន-ការត្រូវ៖

- ប្រមូលឯកសារក្របខ័ណ្ឌគតិយុត្ត រួមមាន គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព សៀវភៅណែនាំ សៀវភៅមេរៀន ឯកសារស្រាវជ្រាវ រួមទាំងរបាយការណ៍វិភាគស្ថានភាពរបស់ក្រុមគោលដៅដែលជាអ្នកផ្តល់សេវានិងទទួលសេវាគាំពារនិងអភិវឌ្ឍកុមារតូច ។ល។
- សង្ខេបខ្លឹមសារក្នុងឯកសារនីមួយៗដើម្បីពិនិត្យមើលបញ្ញត្តិ គោលដៅ គោលបំណង សកម្មភាព និងអនុសាសន៍។
- កត់សម្គាល់គម្លាត ឬអសង្គតិភាពរវាងខ្លឹមសារនៅក្នុងឯកសារនានា។
- កត់សម្គាល់ទម្រង់ និងខ្លឹមសារនានា ពីឯកសារទាំងនេះដែលអាចប្រើប្រាស់សម្រាប់កសាងផែនការសកម្មភាពរាជធានី ខេត្ត នីមួយៗ។
- ចងក្រងបញ្ហាអាទិភាពដែលត្រូវដោះស្រាយ តាមរយៈការបង្កើត និងអនុវត្តផែនការសកម្មភាពរបស់រដ្ឋបាលរាជធានី ខេត្តស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។

## ៤. ប្រមូលទិន្នន័យភស្តុតាងពីសហគមន៍

### ក. ការប្រមូលទិន្នន័យភស្តុតាងពីសហគមន៍

ក្នុងដំណាក់កាលនេះ ក្រុមការងារបច្ចេកទេស ដែលមានសមាសភាពមកពីមន្ទីរ និងទីចាត់ការពាក់ព័ន្ធនឹងវិស័យគាំពារនិងអភិវឌ្ឍន៍កុមារតូច ត្រូវប្រមូលនិងវិភាគទិន្នន័យ និងចងក្រងជារបាយការណ៍ស្រាវជ្រាវ ដែលមានលក្ខណៈវិទ្យាសាស្ត្រសម្រាប់ជាធាតុចូលដើម្បីកសាងផែនការសកម្មភាព។ ទិន្នន័យដែលនឹងត្រូវប្រមូលមានទម្រង់ជាលេខ និងជាអក្សរ ដែលជាមតិយោបល់ផ្ទាល់របស់អ្នកផ្តល់សេវា អ្នកទទួលសេវាដែលជាមាតាបិតា ឬអាណាព្យាបាលកុមារតូច និងកុមារតូច នៅតាមមូលដ្ឋាន ។

### ខ. សារៈសំខាន់នៃការប្រមូលទិន្នន័យភស្តុតាងពីសហគមន៍

ការប្រមូលទិន្នន័យភស្តុតាងពីសហគមន៍ ផ្តល់អត្ថប្រយោជន៍ច្រើនដល់ដំណើរការកសាងផែនការសកម្មភាព។

- **ប្រមូលព័ត៌មានជាក់ស្តែង៖** វាជាទិន្នន័យជាក់ស្តែងដែលបានមកពីអ្នកផ្តល់សេវា អ្នកទទួលសេវាជាស្ត្រី និងអ្នកទទួលសេវាជាកុមារតូច។
- **វាយតម្លៃតម្រូវការ៖** ការប្រមូលទិន្នន័យមូលដ្ឋានពីសហគមន៍នឹងផ្តល់ព័ត៌មានដល់អ្នកកសាងផែនការដឹងច្បាស់អំពីតម្រូវការ បញ្ហាប្រឈម និងការខ្វះចន្លោះនៃការផ្តល់សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូច។
- **សម្រេចចិត្តដោយមានភស្តុតាងច្បាស់លាស់៖** ទិន្នន័យទាំងនេះនឹងផ្តល់ជាមូលដ្ឋានសម្រាប់អ្នកកសាងផែន ធ្វើការសម្រេចចិត្តផ្តល់អាទិភាពចំពោះសកម្មភាពដែលអាចដោះស្រាយបញ្ហាចំពោះមុខ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទទួលសេវា។
- **ចូលរួម៖** ការប្រមូលទិន្នន័យមូលដ្ឋានពីសហគមន៍នឹងធ្វើឱ្យអ្នកផ្តល់សេវា និងទទួលសេវានៅមូលដ្ឋានមានទំនុកចិត្ត និងមោទនភាពចំពោះខ្លួនឯង ដោយសារពួកគាត់បានចូលរួមជាផ្នែកមួយនៃការកសាងផែនការ និងជាអ្នកទទួលផលពីការអនុវត្តផែនការផងដែរ។

### គ. ដំណើរការប្រមូលទិន្នន័យភស្តុតាងពីសហគមន៍

ដំណើរការប្រមូល វិភាគទិន្នន័យ និងសរសេររបាយការណ៍មានលក្ខណៈស្រាវជ្រាវវិទ្យាសាស្ត្រ ដែលមានដំណាក់កាលដូចខាងក្រោម៖

- បង្កើតក្រុមការងារប្រមូល វិភាគទិន្នន័យ និងសរសេររបាយការណ៍ដោយមានការចូលរួមពីភាគីពាក់ព័ន្ធដោយផ្ទាល់ជាពិសេសលើវិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងកិច្ចការនារី។
- រៀបចំឯកសារទស្សនៈទានដែលមានកំណត់ពីគោលបំណង និងវិធីសាស្ត្រនៃការប្រមូលព័ត៌មានមូលដ្ឋានពីសហគមន៍ឱ្យបានច្បាស់លាស់។
- កំណត់ចំនួនក្នុងក្រុមគោលដៅដែលជាអាទិភាពនៃអ្នកផ្តល់សេវា និងទទួលសេវាគាំពារ និងអភិវឌ្ឍន៍កុមារតូច ពោលគឺស្ត្រី និងកុមារតូចអាយុ ០-៦ ឆ្នាំ។
- ប្រើប្រាស់ឧបករណ៍សម្រាប់ប្រមូលទិន្នន័យ ដូចជា កម្រងសំណួរសម្ភាសន៍ដោយផ្អែកលើសមាសធាតុទាំងប្រាំនៃក្របខ័ណ្ឌចិញ្ចឹមបីបាច់កុមារតូចសកល សម្រាប់ក្រុមការងារកសាងផែនការប្រើសម្រាប់សម្ភាសក្រុមគោលដៅ។ សូមមើលកម្រងសំណួរសម្ភាសអ្នកផ្តល់សេវា និងអ្នកទទួលសេវាក្នុងឧបសម្ព័ន្ធ «ង»។
- ចុះប្រមូលទិន្នន័យពីក្រុមគោលដៅតាមពេលវេលា និងចំនួនដែលបានកំណត់។

  វិភាគទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យដើម្បីស្វែងយល់អំពីវិសាលភាពរួម និងគុណភាពនៃការផ្តល់សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូច បញ្ហាប្រឈម និងសំណូមពររបស់ពួកគាត់។
- សរសេររបាយការណ៍ជាទម្រង់សង្ខេបសម្រាប់ធ្វើបទបង្ហាញ និងសម្រង់ដាក់ក្នុងផែនការសកម្មភាពជាពិសេសជំពូកទី២។
- ធ្វើបទបង្ហាញជូនក្រុមកសាងផែនការសកម្មភាពក្រោមការដឹកនាំនិងសម្របសម្រួលពីប្រធាន ឬអនុប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ នៃរាជធានី ខេត្ត ដើម្បីផ្តល់សុពលភាពលើលទ្ធផលដែលទទួលបាន និងប្រើប្រាស់សម្រាប់ដាក់បញ្ចូលក្នុងផែនការសកម្មភាព។

ផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច តម្រូវឱ្យមានការចូលរួមពីមន្ត្រីជំនាញនិងថ្នាក់ដឹកនាំនៃមន្ទីរជំនាញ ដែលជាសមាជិកនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងទីចាត់ការពាក់ព័ន្ធនៃរដ្ឋបាលរាជធានី ខេត្ត។

### ឃ. វិធីសាស្ត្រការប្រមូលគំនិត តាមរយៈកិច្ចប្រជុំពិភាក្សាក្រុម

សកម្មភាពបំផុសគំនិត គឺជាការពិភាក្សា ក្នុងចំណោមសមាជិកក្រុមការងារ ដើម្បីផ្លាស់ប្តូរបទពិសោធ លើស្ថានភាពស្ត្រី និងកុមារតូចបច្ចុប្បន្ន បញ្ហាប្រឈម យុទ្ធសាស្ត្រ និងយន្តការដែលមន្ទីរបានអនុវត្តកន្លងមក ឬ ផ្អែកលើឯកសាររបាយការណ៍ដែលបានវិភាគស្ថានភាពចេញពីមន្ទីរផែនការ និងបទពិសោធផ្ទាល់ចេញពីសហគមន៍។

## សារៈសំខាន់នៃការបំផុសគំនិត

**ការបំផុសគំនិត** ក្នុងចំណោមសមាជិកក្រុមការងារផ្តល់អត្ថប្រយោជន៍ច្រើន សម្រាប់ដំណើរការកសាងផែនការសកម្មភាព។ កន្លងមកភាគីពាក់ព័ន្ធទាំងអស់ពិនិត្យមើលការងារគាំពារនិងអភិវឌ្ឍន៍កុមារតូចពីជ្រុងម្ខាងនៃការងាររៀងៗខ្លួន។ ការប្រជុំពិភាក្សាបំផុសគំនិតនឹងបង្កើតបានជាឱកាសសម្រាប់ភាគីពាក់ព័ន្ធពិនិត្យមើលការគាំពារនិងអភិវឌ្ឍន៍កុមារតូចជាការងារពហុវិស័យ ដែលមានអន្តរកម្មនឹងគ្នាទៅវិញទៅមកក្នុងគោលបំណងរួមគឺ ធានាសុខុមាលភាពកុមារទាំងមូល។ការយល់ដឹងនេះមានសារៈសំខាន់ណាស់សម្រាប់ការកសាងផែនការមួយដែលគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា។

## ជំហានសម្រាប់ការបំផុសគំនិត

ការបំផុសគំនិតនេះអាចនឹងប្រព្រឹត្តទៅដោយការប្រជុំក្នុងចំណោមសមាជិកក្រុមការងារទាំងអស់ដើម្បីឱ្យពួកគាត់មានឱកាសបញ្ចេញមតិចែករំលែកបទពិសោធ លើកឡើងបញ្ហាប្រឈម និងយន្តការដែលពួកគាត់កំពុងអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការគាំពារនិងអភិវឌ្ឍន៍កុមារតូច តាមវិស័យរៀងៗខ្លួន។ សកម្មភាពនៃអង្គប្រជុំនេះស្ថិតក្រោមការសម្របសម្រួលរបស់ប្រធាន ឬអនុប្រធាន គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ថ្នាក់រាជធានី ខេត្ត។ ដើម្បីជាមូលដ្ឋាននៃការពិភាក្សាក្នុងដំណាក់កាលនេះ ការធ្វើបទបង្ហាញដោយតំណាងក្រុមការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច (មន្ទីរផែនការ) សម្រាប់ជាធាតុចូលដ៏សំខាន់ដល់សមាជិកក្រុមពិភាក្សា។ លើសពីនេះទៀត សមាជិកក្រុមការងារត្រូវអានគោលនយោបាយជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ ២០១០ និងផែនការសកម្មភាពជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ ២០២២-២០២៦ និងផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចខេត្តក្រចេះ ខេត្តកំពង់ចាម និងខេត្តរតនគិរី ដើម្បីឱ្យយល់កាន់តែច្បាស់ពីសារៈសំខាន់នៃការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយរបស់កុមារអាយុក្រោម ៦ឆ្នាំ និងយល់ដឹងបន្ថែមអំពីការចូលរួមសហការជាអន្តរវិស័យរបស់មន្ទីរជំនាញពាក់ព័ន្ធ។

### សំណួរគន្លឹះមួយចំនួនសម្រាប់ពិភាក្សាក្នុងដំណាក់កាលនេះមានៈ

- តើការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយរបស់កុមារក្រោមអាយុ ៦ឆ្នាំ មានអ្វីខ្លះ?
- តើកុមារគ្រប់រូប ជាពិសេសកុមារដែលមានពិការភាព រស់នៅតំបន់ដាច់ស្រយាលក្នុងគ្រួសារដែលមានហានិភ័យខ្ពស់បានទទួលការលូតលាស់ពេញលេញឬទេ?
- តើមានកុមារជាច្រើនទៀត ដែលនៅមិនទាន់ទទួលបាន ការចាក់ថ្នាំបង្ការពេញលេញ ការពិនិត្យឱ្យទាន់វេលាអំពីការលូតលាស់ ការចូលរៀនដំបូង ការថែទាំថ្នាក់ថ្នមពីឪពុកម្តាយឬអាណាព្យាបាលដែរទេ?
- ប្រសិនតម្រូវការទាំងអស់នេះមិនបានទទួលពេញលេញ តើដោយសារមូលហេតុអ្វី?
- តើផែនការសកម្មភាពគាំពារនិងអភិវឌ្ឍន៍កុមារតូចថ្នាក់រាជធានី ខេត្ត គួរតែដោះស្រាយបញ្ហាជាអាទិភាពណាខ្លះ?

- តើថ្នាក់ដឹកនាំរាជធានី ខេត្តចង់ឃើញភាពប្រែប្រួលណាខ្លះពាក់ព័ន្ធនឹងស្ថានភាពគាំពារ និងអភិវឌ្ឍន៍កុមារតូច ក្នុងរយៈពេល ៣-៥ ឆ្នាំទៅមុខទៀត?
- តើមន្ទីរធ្វើសកម្មភាពអ្វីខ្លះនៅឆ្នាំកន្លងមក ដែលពាក់ព័ន្ធនឹងការងារគាំពារ និងអភិវឌ្ឍកុមារតូច?
- តើមន្ទីរជួបបញ្ហាលំបាកកម្រិតណា ពាក់ព័ន្ធនឹងសមត្ថភាពមន្ត្រី ថវិកា ផ្នត់គំនិត និងយន្តការអនុវត្ត?
- តើអ្នកណាខ្លះដែលត្រូវចូលរួមបង្កើតផែនការសកម្មភាពនេះ?
- តើយើងត្រូវបង្កើតផែនការសកម្មភាពដោយរបៀបណា?
  - តើមានក្របខ័ណ្ឌឬខ្សែច្រវ៉ាក់លទ្ធផលអ្វីខ្លះសម្រាប់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច?
  - តើសូចនាករអាទិភាព និងពាក់ព័ន្ធអ្វីខ្លះ ដែលត្រូវកំណត់ជាអាទិភាពសម្រាប់វាស់វែងក្របខ័ណ្ឌ ឬខ្សែច្រវ៉ាក់លទ្ធផល? តើត្រូវកំណត់គោលដៅត្រឹមកម្រិតណា និងត្រូវបន្សុីជាមួយនឹងគោលដៅថ្នាក់ជាតិយ៉ាងដូចម្តេច?
  - តើមានសូចនាករណាខ្លះដែលស្របនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាពដែលគួរដាក់បញ្ចូលក្នុងផែនការសកម្មភាព?
  - តើត្រូវមានសកម្មភាពអាទិភាពអ្វីខ្លះ ដើម្បីសម្រេចគោលដៅសូចនាករដែលបានកំណត់ និងត្រូវចាត់អាទិភាពយ៉ាងដូចម្តេច?
  - តើមានតម្រូវការធនធាន(មនុស្ស ថវិកា សម្ភារៈ)អ្វីខ្លះដើម្បីអនុវត្តសកម្មភាព?

កិច្ចប្រជុំពិភាក្សាបំផុសគំនិតនេះនឹងត្រូវកត់ត្រាដោយលេខាកត់ត្រា និងសរសេររបាយការណ៍សម្រាប់ជាធាតុចូលក្នុងការកសាងផែនការសកម្មភាព។

## ជំហានទី៣
## ការរៀបចំ អនុម័ត និងផ្សព្វផ្សាយផែនការសកម្មភាព

### ១. ការរៀបចំសេចក្ដីព្រាងផែនការសកម្មភាព

ផែនការសកម្មភាពថ្នាក់ក្រោមជាតិរបស់រាជធានី ខេត្តនីមួយៗ ត្រូវផ្អែកលើទិន្នន័យមូលដ្ឋានរបស់រាជធានី ខេត្ត ដែលមានក្នុងឯកសារផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល របាយការណ៍វឌ្ឍនភាព ឬរបាយការណ៍របស់មន្ទីរពាក់ព័ន្ធ និងទិន្នន័យមូលដ្ឋានសហគមន៍ ដែលត្រូវប្រមូលជាផ្នែកមួយនៃដំណើរការរៀបចំផែនការសកម្មភាព។ ផែនការសកម្មភាពត្រូវរៀបចំតាមទម្រង់ដែលមាន **៥ជំពូក** សំខាន់ៗ ដូចខាងក្រោម៖

- ១ គោលនយោបាយ និងក្របខ័ណ្ឌការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ២ ស្ថានភាពទូទៅរបស់ស្ត្រី និងកុមារតូចខេត្ត
- ៣ ផែនការសកម្មភាព និងក្របខ័ណ្ឌអនុវត្ត
- ៤ ការត្រួតពិនិត្យ និងវាយតម្លៃ
- ៥ គម្រោងចំណាយ

**ឧបសម្ព័ន្ធ៖** .............

ដើម្បីប្រែក្លាយផែនការសកម្មភាពជាតិ ឱ្យទៅជាផែនការសកម្មភាពរបស់រាជធានី ខេត្ត នីមួយៗ ក្រុមការងារកសាងផែនការសកម្មភាពរបស់រាជធានី ខេត្ត ដែលមានទីចាត់ការផែនការនិងវិនិយោគជាសេ-នាធិការត្រូវ៖

- រៀបចំខ្សែច្រវាក់លទ្ធផលនៃផែនការសកម្មភាពដែលមានធាតុផ្សំដូចជាផលជះ ឬកម្មវិបាក (impact) លទ្ធផល (outcome) ធាតុចេញ (output) សកម្មភាព (acitivity) ធាតុចូល (input) ស្របនឹងខ្សែច្រវាក់លទ្ធផលដែលមាននៅក្នុងផែនការសកម្មភាពជាតិ។
- គណនាថ្លៃចំណាយ ឬតម្រូវការថវិកាសម្រាប់អនុវត្តផែនការសកម្មភាព ។
- ប្រើប្រាស់ខ្លឹមសារ និងទម្រង់នៃជំពូកទី១ ពីផែនការសកម្មភាពជាតិ និងថ្នាក់ក្រោមជាតិដែលមានស្រាប់សម្រាប់បង្កើតខ្លឹមសារជំពូក ដែលឆ្លុះបញ្ចាំងស្ថានភាពទូទៅរបស់រាជធានី ខេត្ត។
- ប្រៀបធៀបស្ថានភាពស្ត្រី និងកុមារអាយុ ០-៦ឆ្នាំ នៅខេត្ត ដែលមានផែនការសកម្មភាពរួចហើយទៅនឹងស្ថានភាពស្ត្រី និងកុមារនៅក្នុងរាជធានី ខេត្ត របស់ខ្លួនតាមរយៈរបាយការណ៍របស់មន្ទីរពាក់ព័ន្ធ និងទិន្នន័យភស្តុតាងពីសហគមន៍ផ្ទាល់ ដើម្បីបង្កើតខ្លឹមសារក្នុងជំពូក២ ស្ដីអំពីស្ថានភាពទូទៅរបស់ស្ត្រី និងកុមារតូចរបស់រាជធានី ខេត្ត។ បើទោះបីជាឧបករណ៍ប្រមូលទិន្នន័យភស្តុតាង

ពីសហគមន៍របស់ខេត្តរតនគិរីត្រូវបានផ្តល់ជាគំរូក៏ដោយខេត្តនីមួយៗត្រូវយកចិត្តទុកដាក់ក្នុង ការកែសម្រួលឧបករណ៍នេះ ដើម្បីប្រមូលទិន្នន័យភស្តុតាងពីសហគមន៍ ដែលឆ្លុះបញ្ចាំងស្ថានភាព ក្នុងរាជធានី ខេត្ត របស់ខ្លួន ជាពិសេសស្ថានភាពកុមាររស់នៅក្នុងគ្រួសារដែលមានហានិភ័យខ្ពស់ ស្ថានភាពរបស់កុមារមានពិការភាព និងកុមាររស់នៅតំបន់ដាច់ស្រយាល ដើម្បីធ្វើឱ្យផែនការសកម្មភាពក្លាយជាផែនការមួយដែលមានបរិយាបន្ន និងសមធម៌ ក្នុងការផ្តល់សេវាគាំពារសំខាន់ៗដល់កុមារ។ លើសពីនេះទៀត ទិន្នន័យរបស់ខេត្តនីមួយៗគួរតែត្រូវបានបង្ហាញ និងពិភាក្សាដោយប្រៀបធៀបទៅនឹងទិន្នន័យថ្នាក់ជាតិ និងទិន្នន័យរបស់ខេត្តដទៃទៀត ដើម្បីជាចំណុចចាប់ផ្តើមសម្រាប់តាមដានវឌ្ឍនភាពនៅឆ្នាំបន្តបន្ទាប់ ក្រោយផែនការសកម្មភាពថ្នាក់ក្រោមជាតិរបស់ខេត្តនីមួយៗត្រូវបានអនុវត្ត។

- កែសម្រួលខ្សែច្រវាក់លទ្ធផលដោយការបន្ថែម ឬបន្ថយលទ្ធផល ធាតុចេញ សកម្មភាព និងធាតុចូលឱ្យសមស្របតាមស្ថានភាពជាក់ស្តែងរបស់ខេត្ត ដោយយកចិត្តទុកដាក់ជាពិសេសបញ្ហាសេដ្ឋកិច្ចសង្គម ជនជាតិដើមភាគតិច ពិការភាព ភេទ និងអប់រំរបស់ស្ត្រី និងកុមារអាយុ ០-៦ ឆ្នាំ។ ផលជះឬកម្មវិបាក (impact) និងលទ្ធផល (outcome) អាចនឹងត្រូវកែសម្រួលបន្តិចបន្តួច ឬរក្សាដដែល ដោយផ្អែកលើបទពិសោធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ខេត្តក្រចេះ និងខេត្តរតនគិរីកន្លងមក។ កិច្ចការទាំងនេះត្រូវធ្វើឡើងជាទម្រង់សិក្ខាសាលា និងកិច្ចប្រជុំច្រើនថ្ងៃ ដោយមានសមាជិកទាំងអស់នៃក្រុមការងារតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងប្រតិបត្តិនៅក្នុងខេត្ត និងបើអាច គួរអញ្ជើញអ្នកជំនាញគាំពារនិងអភិវឌ្ឍកុមារតូចទាំងអ្នកបច្ចេកទេស អ្នកគោលនយោ-បាយ និងអ្នកស្រាវជ្រាវឲ្យចូលរួម។
- ប្រែក្លាយខ្លឹមសារក្នុងខ្សែច្រវាក់លទ្ធផលឱ្យទៅជាទម្រង់ផែនការសកម្មភាពដើម្បីបង្កើតខ្លឹមសារក្នុងជំពូក៣ ស្តីពីផែនការសកម្មភាពផ្អែកលើលទ្ធផល។
- ប្រែក្លាយខ្លឹមសារក្នុងខ្សែច្រវាក់លទ្ធផលទៅជាទម្រង់ក្របខ័ណ្ឌតាមដាននិងវាយតម្លៃលទ្ធផលតាមឆ្នាំនីមួយៗ ដើម្បីបង្កើតជំពូក៤ ស្តីពីក្របខ័ណ្ឌអនុវត្ត តាមដាន និងវាយតម្លៃ។

  ប្រែក្លាយខ្លឹមសារក្នុងខ្សែច្រវាក់លទ្ធផលទៅជាទម្រង់គម្រោងចំណាយថវិកាតាមសកម្មភាពតាមឆ្នាំនីមួយៗ ដើម្បីបង្កើតជំពូក៥ ស្តីពីគម្រោងចំណាយ។
- បញ្ចូលខ្លឹមសារទាំងអស់ពីជំពូក១ ដល់ជំពូក៥ ដើម្បីបង្កើតសេចក្តីព្រាងលើកទី១នៃផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចរបស់ខេត្ត។
- បន្ទាប់ពីសេចក្តីព្រាងផែនការសកម្មភាព ត្រូវបានរៀបចំដែលដឹកនាំដោយទីចាត់ការផែនការ និងវិនិយោគ ប្រធានក្រុមការងារកសាងផែនការត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់មុននឹងដាក់ឆ្លងគណៈអភិបាល និងក្រុមប្រឹក្សាដើម្បីអនុម័ត។

## ២. ការផ្ទៀតផ្ទាត់ និងបញ្ចប់ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវសកម្មភាព សូចនាករធាតុចេញ និងថវិកាតាមឆ្នាំ សមាជិកនៃក្រុមការងារត្រូវដឹកនាំការប្រជុំដែលមានការចូលរួមពីមន្ទីរជំនាញ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីទទួលបន្ទុកការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច។

- អានខ្លឹមសារទាំងអស់នៃសេចក្តីព្រាងផែនការសកម្មភាពដោយយកចិត្តទុកដាក់ ដើម្បីផ្ទៀងផ្ទាត់ទៅនឹងបទពិសោធ និងស្ថានភាពនៅក្នុងមន្ទីររបស់ខ្លួន ជាពិសេស អំពីសកម្មភាព តួលេខស្តីពីស្ថានភាពស្ត្រី និងកុមារអាយុ ០-៦ ឆ្នាំ ដោយយកចិត្តទុកដាក់ជាពិសេសដល់ស្ថានភាពរបស់កុមាររស់នៅក្នុងគ្រួសារដែលមានហានិភ័យខ្ពស់ កុមារមានពិការភាព និងកុមារនៅតំបន់ដាច់ស្រយាល ដើម្បីពង្រឹងសមធម៌ និងបរិយាបន្ន ដល់កុមារទាំងនេះឱ្យទទួលបានសេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចដូចកុមារដទៃទៀត។
- បំពេញ និងផ្ទៀងផ្ទាត់សូចនាករដើមគ្រា សូចនាករតាមឆ្នាំ ដោយពិនិត្យមើលឱ្យច្បាស់លាស់អំពីលទ្ធភាពដែលអាចសម្រេចបានតាមឆ្នាំនីមួយៗ មធ្យោបាយនៃការប្រមូលទិន្នន័យដើម្បីវាយតម្លៃវឌ្ឍនភាព និងអ្នកទទួលខុសត្រូវ។
- បំពេញខ្ទង់ថវិកា ផ្អែកលើខ្ទង់ចំណាយឆ្នាំចាស់សម្រាប់សកម្មភាពដែលបានអនុវត្តកន្លងមក និងប្រមើលមើលខ្ទង់ចំណាយរបស់សកម្មភាពចាស់ សម្រាប់ឆ្នាំថ្មី និង/ឬ សកម្មភាពថ្មីតាមលទ្ធភាពជាក់ស្តែង ឬតាមការប៉ាន់ស្មាន បើទោះបីជាពេលកសាងផែនការមិនទាន់មានប្រភពថវិកាក៏ដោយ
- សម្របសម្រួលជាមួយប្រធាន ឬអនុប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារថ្នាក់រាជធានី ខេត្តក្នុងករណីមិនច្បាស់លាស់ដើម្បីសុំការបញ្ជាក់។
- រៀបចំសិក្ខាសាលា ឬ ប្រជុំពិភាក្សារវាងសមាជិកទាំងអស់នៃក្រុមការងាររាយការណ៍វឌ្ឍនភាព លើកឡើងបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយរួមគ្នាពាក់ព័ន្ធនឹងចំណុចណាមួយនៃផែនការសកម្មភាព ដូចជា សកម្មភាព សូចនាករតាមដាន និងថវិកា។ល។
- បែងចែកការងារក្នុងសមាជិកក្រុមការងារមកពីមន្ទីរពាក់ព័ន្ធនីមួយៗ ទទួលខុសត្រូវអានសេចក្តីព្រាងចុងក្រោយនៃផែនការសកម្មភាពដោយពិនិត្យមើលទាំងភាពត្រឹមត្រូវ និងភាពងាយស្រួលអាននៃសំណេរ និងខ្លឹមសារជាតួលេខដើម្បីធានាសង្គតិភាពចាប់តាំងពីជំពូក១ រហូតដល់ជំពូក៥។
- រៀបចំរចនាបថនៃផែនការសកម្មភាពតាំងពីក្របខាងមុខ រហូតដល់ក្របខាងក្រោយដើម្បីឱ្យមានភាពស្អាតបាត និងសង្គតិភាព ទាំងរូបភាព ទាំងតារាងឱ្យមានភាពទាក់ទាញ។
- ដាក់សេចក្តីព្រាងចុងក្រោយជូន ប្រធាន និងអនុប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានីខេត្តដែលជាប្រធានក្រុមការងារផែនការសកម្មភាពដើម្បីសំយោគពិនិត្យ និងសម្រេចជា ផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ខេត្ត.......... ឆ្នាំ ...... - ......។

## ៣. ការអនុម័ត និងផ្សព្វផ្សាយ

ក្រោយពេល ប្រធាន អនុប្រធាន និងក្រុមការងារបានពិនិត្យនិងផ្ទៀងផ្ទាត់លើសេចក្តីព្រាងរួច ប្រធានក្រុមការងាររាជធានី ខេត្ត រៀបចំសំណើរសុំការអនុម័តពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងផ្សព្វផ្សាយផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច។ សំណើរសុំការអនុម័តត្រូវភ្ជាប់ជាមួយនូវរបាយការណ៍សង្ខេបនៃការកសាងផែនការសកម្មភាព តាំងពីជំហ៊ានដំបូង រហូតដល់សម្រេចបានសេចក្តីព្រាងចុងក្រោយ។

បន្ទាប់ពីទទួលបានចំណារឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានក្រុមការងារត្រូវរៀបចំបោះពុម្ពផែនការសកម្មភាពសម្រាប់ប្រកាសផ្សព្វផ្សាយដាក់ឱ្យអនុវត្ត និងចែករំលែកបទពិសោធដល់បណ្តាខេត្តផ្សេងៗទៀត ដែលមានបំណងចង់រៀបចំផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅក្នុងខេត្តរបស់ខ្លួនដែរ។

សកម្មភាពនៃការប្រកាសផ្សព្វផ្សាយដាក់ឱ្យអនុវត្ត និងចែករំលែកបទពិសោធគួរតែធ្វើឡើងក្នុងទម្រង់ជាសិក្ខាសាលា ដែលមានបទបង្ហាញអំពីផែនការសកម្មភាព ដំណើរការកសាងផែនការសកម្មភាព និងទស្សនកិច្ចសិក្សាទៅតាមមូលដ្ឋានដែលផ្តល់សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចដើម្បីឱ្យគណៈប្រតិភូមកពីថ្នាក់ជាតិដែលជាសមាជិកនៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច និងពីថ្នាក់ខេត្ត ដែលមានប្រធាន ឬអនុប្រធាននៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី ខេត្ត និងអង្គការពាក់ព័ន្ធនឹងគម្រោងគាំពារ និងអភិវឌ្ឍកុមារតូចបានស្វែងយល់បន្ថែមពីការផ្តល់ និងការទទួលសេវាគាំពារ និងអភិវឌ្ឍកុមារតូចជាក់ស្តែងនៅសហគមន៍ ។

ក្រោយពេលផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារត្រូវបានដាក់ឱ្យអនុវត្ត កិច្ចការបន្ទាប់គឺការតាមដានការអនុវត្ត និងលទ្ធផលដែលទទួលបានពោលគឺ

- ធ្វើការតាមដានការអនុវត្តសកម្មភាពប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ( សូចនាករ ធាតុចេញ Output )។
- ធ្វើការតាមដានវឌ្ឍនភាពប្រចាំឆ្នាំ ( សូចនាករលទ្ធផល Outcome )។

## ឧបសម្ព័ន្ធ ក
# តារាងផែនការសកម្មភាព និងគម្រោងចំណាយ

## តារាងផែនការសកម្មភាព

| លទ្ធផល | សកម្មភាព | សូចនាករ ជាតុចេញ | សូចនាករតាមឆ្នាំ | | | អង្គភាព ទទួលខុសត្រូវ | ប្រភព សូចនាករ |
|---|---|---|---|---|---|---|---|
| | | | ២០២៦ | ២០២៧ | ២០២៨ | | |
| ១. សុខភាព៖ សុខភាពមាតា ទារក និងកុមារតូចត្រូវបានលើកកម្ពស់ | | | | | | | |
| ១.១ | ១.១.១ | | | | | | |
| | ១.១.២ | | | | | | |
| | ១.១.៣ | | | | | | |
| ១.២ | ១.២.១ | | | | | | |

## គម្រោងចំណាយថវិកាតាមសកម្មភាពក្នុងសមាសធាតុនីមួយៗ

| សកម្មភាព | ថវិកាតាមឆ្នាំ(លានរៀល) | | | អង្គភាព ទទួលខុសត្រូវ | ប្រភពថវិកា |
|---|---|---|---|---|---|
| | ២០២៦ | ២០២៧ | ២០២៨ | | |
| ១. សុខភាព៖ សុខភាពមាតា ទារក និងកុមារតូចត្រូវបានលើកកម្ពស់ | | | | | |
| ១.១.១ | | | | | |
| ១.១.២ | | | | | |
| ១.១.៣ | | | | | |
| ១.២.១ | | | | | |
| ១.២.២ | | | | | |

## ឧបសម្ព័ន្ធ ២

# តារាងក្របខណ្ឌតាមដាន និងវាយតម្លៃ និងតារាងតក្កវិជ្ជា

## តារាងក្របខ័ណ្ឌតាមដាននិងវាយតម្លៃលទ្ធផលតាមឆ្នាំ

| ល.រ. | លទ្ធផល | លទ្ធផលដើមគ្រា | លទ្ធផលតាមឆ្នាំ | | | អង្គភាពទទួលខុសត្រូវ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|
| | | | ២០២៦ | ២០២៧ | ២០២៨ | | |
| ១.១ | | | | | | | |
| ១.២ | | | | | | | |
| ១.៣ | | | | | | | |
| ១.៤ | | | | | | | |

## ខ្សែច្រវាក់លទ្ធផលស្តីពីទំនាក់ទំនងរវាងផលជះ លទ្ធផល ធាតុចេញ សកម្មភាព និងធាតុចូល

| ផលជះឬកម្មវិបាក Impact | កុមារតូចអាយុ០-៦ឆ្នាំក្នុងខេត្ត.... ជាពិសេស កុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ និងកុមារជនជាតិ ទទួលបានសេវាគាំពារគ្រប់សមាសធាតុទាំងប្រាំនៃក្របខ័ណ្ឌចិញ្ចឹមបីបាច់ដើម្បីអភិវឌ្ឍខ្លួនក្លាយជាពលរដ្ឋពេញលេញ | | | | | |
|---|---|---|---|---|---|---|
| **លទ្ធផល Outcome** | សុខភាពមាតាទារក និងកុមារតូចត្រូវបានលើកកម្ពស់ (Health) | អាហារូបត្ថម្ភគ្រប់គ្រាន់ត្រូវបានផ្តល់ដល់ស្ត្រីនិងកុមារតូច (Nutrition) | កុមារតូចត្រូវបានចិញ្ចឹមបីបាច់ដោយការឆ្លើយតបនិងភាពកក់ក្តៅ (Responsive Care) | ឱកាសសម្រាប់ការរៀនទាន់ពេលប្រកបដោយគុណភាព សមធម៌ និងបរិយាបន្នត្រូវបានផ្តល់ដល់កុមារតូចគ្រប់រូប (Early Learning) | សន្តិសុខនិងសុវត្ថិភាពរបស់កុមារតូចត្រូវបានធានា (Child safety and security) | យន្តការសម្របសម្រួលការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច និងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិត្រូវបានពង្រឹង (ECCD គោលដៅ ៤) |
| **លទ្ធផល Result** | | | | | | |
| **ធាតុចេញ Output** | | | | | | |
| **សកម្មភាព Activity** | | | | | | |
| **ធាតុចូល (Input)** | | | | | | |

## ឧបសម្ព័ន្ធ គ

## ឯកសារគ្រប់ខ័ណ្ឌគតិយុត្ត

១. ក្រសួងកិច្ចការនារី (២០១៧) យុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន

២. ក្រសួងកិច្ចការនារី (២០១៧) ឧបករណ៍ផ្សព្វផ្សាយសកល (កម្រិត១) នៃយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន

៣. ក្រសួងមហាផ្ទៃ (២០២២) សៀវភៅណែនាំស្តីពី ការគ្រប់គ្រងដំណើរការអប់រំឪពុកម្តាយអាណាព្យាបាលក្នុងការគាំពារនិងអភិវឌ្ឍន៍កុមារតូច សម្រាប់ឃុំ សង្កាត់

៤. ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ស្តង់ដាអប្បបរមាមត្តេយ្យសិក្សាសហគមន៍

៥. គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច (២០២២) ការចិញ្ចឹមបីបាច់កុមារតូច

៦. រដ្ឋបាលខេត្តក្រចេះ (២០២៣) ផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ២០២៣-២០២៥

៧. រដ្ឋបាលខេត្តរតនគិរី (២០២៣) ផែនការសកម្មភាពថ្នាក់ក្រោមជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ២០២៤-២០២៦

៨. រាជរដ្ឋាភិបាល (២០១០) គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច

៩. រាជរដ្ឋាភិបាល (២០២២) ផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ២០២២-២០២៦

១០. វិទ្យាស្ថានជាតិស្ថិតិ (NIS) (២០២០) ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩

១១. វិទ្យាស្ថានជាតិស្ថិតិ (NIS) [កម្ពុជា] ក្រសួងសុខាភិបាល (MOH) [កម្ពុជា] និង ICF (២០២២) អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២២ របាយការណ៍សូចនាករស្នូល

១២. វិទ្យាស្ថានជាតិស្ថិតិ (២០២២) របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០២១

## ឧបសម្ព័ន្ធ ឃ

# គម្រូទសំណួរប្រមូលទិន្នន័យតស្តុតាងពីសហគមន៍

## ម្រូទសំណួរសម្ភាសប្រមូលទិន្នន័យមូលដ្ឋានពីសហគមន៍

ខេត្តៈ .................. ស្រុកៈ .................. ឃុំៈ .................. ភូមិៈ ..................

កាលបរិច្ឆេទៈ .................. ទីតាំងៈ ..................

### កិច្ចពិភាក្សាជាមួយកុមារតូចៗ និងអាណាព្យាបាល នៅក្នុងសាលាមត្តេយ្យសហគមន៍

| សំណួរ | សង្ខេប |
|---|---|
| តើអ្វីដែលធ្វើឱ្យកុមារសប្បាយចិត្ត? | |
| សម្រង់សម្ដីដើម | |
| តើអ្វីដែលធ្វើឱ្យកុមារមិនសប្បាយចិត្ត? | |
| តើគេចូលចិត្តធ្វើរឿងអ្វីជាងគេ? | |
| សម្រង់សម្ដីដើម | |

### កិច្ចពិភាក្សាជាមួយអាណាព្យាបាលនៅសាលាភូមិ

| សំណួរ | ការឆ្លើយតប | សម្រង់សម្ដីដើម |
|---|---|---|
| ១. ដើម្បីឱ្យកុមារមានការលូតលាស់បានល្អ គិតចាប់ពីពេលដែល ចាប់កំណើតក្នុងផ្ទៃម្ដាយរហូតដល់អាយុ ៦ឆ្នាំ តើឪពុកម្ដាយ ឬអាណាព្យាបាលត្រូវចិញ្ចឹមបីបាច់ថែរក្សាដូចម្ដេចខ្លះ? (សមាសធាតុនៃការក្របខ័ណ្ឌចិញ្ចឹមបីបាច់សកលៈ សុខភាព អាហារូបត្ថម្ភ ទឹកស្អាតអនាម័យ ការអប់រំ កិច្ចការពារកុមារ ការការពារសង្គម) | ១. សុខភាពៈ<br>២. អាហារូបត្ថម្ភៈ<br>៣. ការចិញ្ចឹមបីបាច់ៈ<br>៤. សុវត្ថិភាព/សន្តិសុខៈ<br>៥. ឱកាសរៀនទាន់ពេលៈ | |

| | | |
|---|---|---|
| **លទ្ធភាពទទួលបានសេវា អ.វ.ក.តៈ**<br>**២.** តើនៅក្នុងតំបន់នេះស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម៦ឆ្នាំ បានទទួលសេវាអ្វីខ្លះ? | ១. សុខភាព៖<br>២. អាហារូបត្ថម្ភ៖<br>៣. ការចិញ្ចឹមបីបាច់៖<br>៤. សុវត្ថិភាព/សន្តិសុខ៖<br>៥. ឱកាសរៀនទាន់ពេល៖ | |
| **៣.** សូមអ្នកជួយប្រាប់អំពីបទពិសោធរបស់អ្នក(គំនិត/អារម្មណ៍) ក្នុងការទទួលសេវា (សួរម្តងមួយតាមប្រធានបទខាងលើ) អ្វីដែលអ្នកមិនពេញចិត្តជាងគេ? ហេតុអ្វី? | ១. សុខភាព៖<br>២. អាហារូបត្ថម្ភ៖<br>៣. ការចិញ្ចឹមបីបាច់៖<br>៤. សុវត្ថិភាព/សន្តិសុខ៖<br>៥. ឱកាសរៀនទាន់ពេល៖ | |
| **៤.** សូមអ្នកជួយប្រាប់អំពីបទពិសោធរបស់អ្នក(គំនិត/អារម្មណ៍) ក្នុងការទទួលសេវា (សួរម្តងមួយតាមប្រធានបទខាងលើ) អ្វីដែលអ្នកពេញចិត្តបំផុត? ហេតុអ្វី? | ១. សុខភាព៖<br>២. អាហារូបត្ថម្ភ៖<br>៣. ការចិញ្ចឹមបីបាច់៖<br>៤. សុវត្ថិភាព/សន្តិសុខ៖<br>៥. ឱកាសរៀនទាន់ពេល៖ | |

| | | |
|---|---|---|
| ៥. តើអ្នកមានសំណូមពរអ្វីខ្លះសម្រាប់ធ្វើឱ្យប្រសើរឡើងនូវសេវាសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ៦ឆ្នាំ (មាន/អាចទទួលបានគុណភាពឥរិយាបថ/អាកប្បកិរិយារបស់អ្នកផ្តល់សេវា) | ១. សុខភាព៖<br><br>២. អាហារូបត្ថម្ភ៖<br><br>៣. ការចិញ្ចឹមបីបាច់៖<br><br>៤. សុវត្ថិភាព/សន្តិសុខ៖<br><br>៥. ឱកាសរៀនទាន់ពេល៖ | |

## កិច្ចពិភាក្សាជាមួយអ្នកផ្តល់សេវានៅសាលាឃុំ

| ចង្អុលបង្ហាញសមាសធាតុនៃការចិញ្ចឹមបីបាច់ | សេវាកម្មដែលបានផ្តល់ជូន | រីករាយ (បាទ/ចាសឬទេ) | បញ្ហាប្រឈម | អនុសាសន៍សម្រង់សម្តី |
|---|---|---|---|---|
| សុខភាព | | | | |
| អាហារូបត្ថម្ភ | | | | |
| ការចិញ្ចឹមបីបាច់ | | | | |
| សុវត្ថិភាព/សន្តិសុខ | | | | |
| ឱកាសរៀនទាន់ពេល | | | | |
| បញ្ហាប្រឈមទូទៅ | | | | |

## ឧបសម្ព័ន្ធ ខ
## ទម្រង់គំរូសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូច

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត....**
លេខ......./ស.ស.រ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូច**

**អភិបាល នៃគណៈអភិបាលខេត្ត........**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខនស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ខែកញ្ញាឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្កជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣១៧ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
- បានឃើញអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច
- បានឃើញបានប្រកាសលេខ ៤៨០៧ ប្រ.ក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃរដ្ឋបាល រាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ
- យោងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០២២-២០២៦
- យោងសេចក្តីសម្រេចលេខ..........ចុះថ្ងៃទី.....ខែ............ឆ្នាំ២០២៥ សៀវភៅណែនាំ
- ស្តីពីការកសាងផែនការសកម្មភាពថ្នាក់ក្រោមជាតិសម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- ស្មារតីអង្គប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត កាលពីថ្ងៃទី.....ខែ......ឆ្នាំ២០២៥
- ..........................................................................................................។

## សម្រេច

**ប្រការ១. គោលបំណង**

ត្រូវបានរៀបចំ បង្កើតក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្ត គោលនយោបាយជាតិគាំពារ និងអភិវឌ្ឍន៍ កុមារតូចឆ្នាំ២០១០ ផែនការសកម្មភាពជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ ២០២២ - ២០២៦ និងការចូលរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០៣០ ពាក់ព័ន្ធនឹងកុមារតូច។

**ប្រការ២. រចនាសម្ព័ន្ធក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត**

ក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារ តូចរាជធានី ខេត្ត គឺជាក្រុមការងារមួយរបស់គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដើម្បីអនុវត្តការងារគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ លោកជំទាវ........... | សមាជិកក្រុមប្រឹក្សាខេត្ត | ជាប្រធានកិត្តិយស |
| ២. លោក លោកស្រី........... | អភិបាលរងខេត្ត(ទទួលបន្ទុក) | ជាប្រធានការងារ |
| ៣. លោក លោកស្រី........... | នាយករដ្ឋបាល | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៤. លោក លោកស្រី........... | ប្រធានឬអនុប្រធានមន្ទីរអប់រំ... | ជាសមាជិក |
| ៥. លោក លោកស្រី........... | ប្រធានឬអនុប្រធានមន្ទីរសុខាភិបាល | ជាសមាជិក |
| ៦. លោក លោកស្រី........... | ប្រធានឬអនុប្រធានមន្ទីរសង្គមកិច្ច | ជាសមាជិក |
| ៧. លោក លោកស្រី........... | ប្រធានឬអនុប្រធានមន្ទីរកិច្ចការនារី... | ជាសមាជិក |
| ៨. លោក លោកស្រី........... | ប្រធានឬអនុប្រធានមន្ទីរផែនការ... | ជាសមាជិក |
| ៩. លោក លោកស្រី........... | ប្រធានឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ១០. លោក លោកស្រី......... | ប្រធានឬអនុប្រធានមន្ទីរបរិស្ថាន | ជាសមាជិក |
| ១១. លោក លោកស្រី......... | ប្រធានឬអនុប្រធានមន្ទីរកសិកម្ម... | ជាសមាជិក |
| ១២. លោក លោកស្រី......... | ប្រធានឬអនុប្រធានមន្ទីរព័ត៌មាន | ជាសមាជិក |
| ១៣. លោក លោកស្រី......... | ប្រធានឬអនុប្រធានមន្ទីរសេដ្ឋកិច្ច... | ជាសមាជិក |
| ១៤. លោក លោកស្រី......... | នាយកឬនាយករងទីចាត់ការផែនការ... | ជាសមាជិក |
| ១៥. លោក លោកស្រី......... | នាយកឬនាយករងទីចាត់ការហិរញ្ញវត្ថុ... | ជាសមាជិក |
| ១៦. លោក លោកស្រី......... | នាយកឬនាយករងទីចាត់ការអន្តរវិស័យ... | ជាសមាជិក |
| ១៧. លោក លោកស្រី......... | តំណាងដៃគូអភិវឌ្ឍន៍......... | ជាសមាជិក |
| ១៨. លោក លោកស្រី......... | (អាចបន្ថែមតាមការចាំបាច់) | ជាសមាជិក |

**ប្រការ៣. តួនាទី ភារកិច្ចរបស់ក្រុមការងារកសាងផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត**

- រៀបចំកិច្ចប្រជុំក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍកុមារតូចថ្នាក់រាជធានី ខេត្ត
- រៀបចំផែនការការងារកសាងផែនការគាំពារ និងអភិវឌ្ឍកុមារតូចស្របតាមសៀវភៅណែនាំ
- បែងចែកតួនាទីភារកិច្ចសមាជិកសមាជិកានៃក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូចដើម្បីអនុវត្តសកម្មភាពនានាក្នុងផែនការការងារដែលបានរៀបចំ
- រៀបចំសេចក្តីព្រាងផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត
- សម្របសម្រួលជាមួយក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈកម្មការផ្សេងៗទៀត ប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើបច្ចុប្បន្នភាព និងរាយការណ៍អំពីស្ថានភាពនៃវឌ្ឍនភាព កសាងផែនការសកម្មភាព
- កៀរគរដៃគូពាក់ព័ន្ធដើម្បីចូលរួមរៀបចំផែនការសកម្មភាពស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូចថ្នាក់រាជធានី ខេត្ត

- ពិគ្រោះយោបល់លើសេចក្តីព្រាងផែនការជាមួយរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភាគីពាក់ព័ន្ធដើម្បីប្រមូលមតិយោបល់ និងធាតុចូលបន្ថែម
- រៀបចំបញ្ចប់សេចក្តីព្រាងផែនការ និងស្នើសុំការអនុម័តផែនការពីក្រុមប្រឹក្សា
- ផ្សព្វផ្សាយផែនការដល់ភាគីពាក់ព័ន្ធ
- បញ្ចូលសកម្មភាពសំខាន់ៗពាក់ព័ន្ធផែនការសកម្មស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច ទៅក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ ៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- គាំទ្រ ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំ ដោយមានកំណត់ហេតុច្បាស់លាស់ស្តីពីលទ្ធផល នៃការអនុវត្តផែនការ បញ្ហាប្រឈម និងសកម្មភាពដែលត្រូវអនុវត្តបន្ត
- សម្របសម្រួលប្រមូល រៀបចំ និងបញ្ជូនរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំមកលេខាធិការដ្ឋានគាំពារ និងអភិវឌ្ឍន៍កុមារតូចថ្នាក់ជាតិ ព្រមទាំងផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពជាសាធារណៈ
- ទំនាក់ទំនងជាមួយអគ្គលេខាធិការដ្ឋានគាំពារនិងអភិវឌ្ឍន៍កុមារតូច ដើម្បីសុំការគាំទ្របច្ចេកទេស និងការណែនាំផ្សេងៗ។

**ប្រការ៤. អំពីការប្រព្រឹត្តទៅរបស់ក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត**

ក្រុមការងារត្រូវមានលេខាធិការដ្ឋានដែលស្ថិតនៅក្រោមទីចាត់ការផែនការ និងវិនិយោគ នៃរដ្ឋបាលរាជធានី ខេត្ត ធ្វើជាសេនាធិការគាំទ្រប្រធានក្រុមការងារក្នុងដំណើរការរៀបចំផែនការសកម្មភាពគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត។

**ប្រការ៥. អំពីខ្សែគណនេយ្យភាពក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត**

ក្រុមការងារកសាងផែនការគាំពារ និងអភិវឌ្ឍន៍កុមារតូចរាជធានី ខេត្ត គឺជាក្រុមការងារមួយរបស់គណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការ ស្ត្រី និងកុមារ ដូច្នេះក្រុមការងារនេះត្រូវមានគណនេយ្យភាពចំពោះគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ ស្ត្រីនិងកុមារ។ ចំណែក សមាជិកនៃក្រុមការងារនេះ ត្រូវមានគណនេយ្យភាពចំពោះប្រធានអង្គភាពស្ថាប័នរបស់ខ្លួនរៀងៗខ្លួន។

**ប្រការ៦.**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.**

គ្រប់អង្គភាព ស្ថាប័នក្នុងដែនសមត្ថកិច្ចរដ្ឋបាលរាជធានី ខេត្ត...និងសាមីខ្លួនត្រូវ អនុវត្តតាមសេចក្តី សម្រេចនេះតាមសមត្ថកិច្ចរៀង ៗខ្លួនឱ្យមានប្រសិទ្ធភាពចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ............................ ខែ.............. ឆ្នាំ.......... ..... ព.ស.២៥៦......

.................... ថ្ងៃទី............ ខែ............. ឆ្នាំ២០២......

**អភិបាលខេត្ត**

ចម្លងជូន៖

- ...........
- ...........
- ...........

.....................

**អគ្គលេខាធិកាដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច**
**អាសយដ្ឋាន៖** លេខ ២០១ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
**ហ្វេសប៊ុក៖** ECCD Cambodia; **Youtube**: ECCD Cambodia

ឧបត្ថម្ភដោយ៖ unicef
ដើម្បីកុមារគ្រប់រូប